# ការសំភាស៍របស់បងស្រី សាយ ស្រស់

កះ អ្នកសំភាស៍គេ អ៊ុំ ធីដា ខះ អ្នកដែលត្រូវគេនិងសំភាស៍ សាយ ស្រស់

កះ ជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់បងដែលបងអោយខ្ញុំនិងធ្វើការសំភាស៍ជីវប្រវិត្តរបស់បងហើយការសំភាស៍មួយនេះគឺធ្វើឡើងដោយសកលវិទ្យាល័យBYUហើយសកលវិទ្យាល័យនិងចង់ថៃរក្សាជីវប្រវិត្តជីដូនជីតារបស់បងហើយក៏ទុកអោយកូនចៅជំនាន់ក្រោយរបស់បងនិងបានយល់បានដឹងពីជីវប្រវត្តរបស់បងនិងរួចហើយខ្ញុំអាចសុំបងដាក់ការសំភាស៍មួយនេះនៅក្នុងវើកផ្សាយរបស់សកលវិទ្យាល័យមួយនិងផងដែល។ ហើយខ្ញុំឈ្មោះថា អ៊ុំ ធីដាធ្វើការសំភាស៍នេះនៅថ្ងៃទី01 ខែ 01 ឆ្នាំ 2018 ។ហើយបងយល់ព្រមអោយខ្ញុំនិងដាក់ការសំភាស៍របស់បងនិងនៅក្នុងវើកផ្សាយរបស់សកលវិទ្យាល័យមួយនេះដែលទេបង។

ខះ ចង់សួរថាមិចដែលអូន?

កះ ចាអញ្ចឹងតើបងអាចអោយខ្ញុំដាក់ការសំភាស៍មួយនិងនៅក្នុងវើកផ្សាយរបស់សកលវិទ្យាល័យមួយនិងបានទេបង?

ខះ បានអូន។

កះ អញ្ចឹងអរគុនច្រើនបងថាតើបងមានឈ្មោះអ្វីមានត្រគោលអ្វីដែលបង?

ខះ បងឈ្មោះថាស្រស់នាមត្រគោលគឺសាយ។

កះ សាយ ស្រ....។

ខះ សាយ ស្រស់។

កះ អរអញ្ចឹងតើបងមានឈ្មោះហៅក្រៅដែលទេបងហើយចុះតើបងមានឈ្មោះកាលពីក្មេងដែលទេបង?ឈ្មោះហៅក្រៅអីក៏មិនមានដែលន៏បង?

ខះ អត់មានទេ។

កះ ហើយតើបងមានអាយុប៉ុន្មានដែលបង?

ខះ 35ឆ្នាំ។

កៈ អរគុណច្រើនបងហើយតើបងកើតនៅឆ្នាំណាដែលបង។

ខៈ កើតនៅឆ្នាំ1983។

កៈ អញ្ចឹងតើឆ្នាំច័ន្ទគិតតើបងកើតនៅឆ្នាំមួយណាដែលបង?ដូចជាឆ្នាំជូត ឆ្នាំថោះ ឆ្នាំអីអញ្ចឹងបងហើយតើបងនិងកើតនៅឆ្នាំមួយណាដែលបង?

ខៈ បងកើតនៅឆ្នាំថោះ។

កៈ ចាអញ្ចឹងតើបងទីកន្លែងកណើតរបស់បងនៅកន្លែងណាដែលបង?

ខៈ ភូមិខ្លុយកើត ឃុំ សញ្ជ្វង ស្រុកបារ៉ាយ ខេត្តកំពង់ធំ។

កៈ អញ្ចឹងតើបងមានបងប្អូនចំនួនប៉ុន្មាននាក់ដែលបង?

ខៈ បងមានបងប្អូនចំនួនប្រាំពីរនាក់។

កៈ អញ្ចឹងបងមានបងប្អូនចំនួនប្រាំពីរអ្នក។ចាបងអញ្ចឹងបងតើបងជាកូនទីប៉ុន្មានដែលបង?

ខៈ ជាកូនទីប្រាំ។

កៈ ជាកូនទីប្រាំហើយតើបងប្អូនរបស់បងមានឈ្មោះអ្វីខ្លះដែលទៅបង?

ខៈ បងគេបង់អស់គឺមានឈ្មោះថាសាយ ហេង ហើយបងទីពីរមានឈ្មោះថាសាយ ហៀង ហើយបងស្រីទីបីនិងគាត់មានឈ្មោះថាសាយ មុំ ហើយបងទីបួនគាត់មានឈ្មោះថាសាយ ម៉ៅហើយពេល ប្អូនបន្ទាប់ខ្ញុំទីប្រាំមួយគាត់មានឈ្មោះថាសាយ សៀងហើយប្អូនពៅ គាត់ឈ្មោះថាសាយម៉ាប់។

កៈ គាត់ឈ្មោះថាសាយ ម៉ាប់មកពីគាត់និងម៉ាប់មែនបង?

ខៈ អត់ទេមានណាគាត់ស្គមតែដោយសារតែឈ្មោះវាជាប់អញ្ចឹង និង។

កៈ
ចាអញ្ចឹងតើបងមានអនុស្សាវរីន៍អ្វីខ្លះជាមួយនិងពួកគាត់បង?បងអាចជួយរៀបរាប់បានទេបង?

ខៈ
និយាយទៅមានច្រើននៅពេលដែលយើងនៅក្មេងៗពេលដែលយើងធ្វើអីក៏យើងនិងអត់ពីបាកដែលយើងដឹងថាពេលដែលហូបឆ្អែតហើយលេងដល់ពេលដែលចូលគេងប្រហែលគ្នាហើយបងប្អូនស្រីតែបើបងប្អូនប្រុសវីញពួកយើងនិងកឹអត់ទាន់ជិតស្និតអីនោះទេព្រោះអីបងប្រុសរបស់យើងនិងគឺពួកគាត់និងធំៗពួកគាត់និងប្រុសហើយពួកយើងស្រីៗដូចគ្នាអីអញ្ចឹ

ងបានប្រលែងជាមួយនិងគ្នាបានតែអនុស្សាវរីន៍ជាមួយនិងបងៗគ្នាប៉ុន្មានអីទេព្រោះអីបងគាត់ចេញទៅធ្វើការងារអីនិងអស់ហើយនិងព្រោះអីគ្រួសាររបស់ពួកយើងមានការខ្វះខាតដល់អញ្ចឹងទៅដឹងខំប្រឹងរកអីអញ្ចឹងទៅបងៗគាត់ខំប្រឹងរកលុយបានធ្វើផ្ទះអីអញ្ចឹងទៅណាពេលដែលផ្ទះនិងធ្វើបានប៉ុន្មានឆ្នាំបានឪពុករបស់ខ្ញុំនិងស្លាប់ទៅហើយឪពុករបស់ខ្ញុំនិងគាតស្លាប់តាំងពីដប់ឆ្នាំជាងមកហើយនិងតែតាំងពីគាត់និងស្លាប់មកគ្រួសារពួកយើងមានការលំបាកច្រើនណាស់ដល់ពេលអញ្ចឹងពួកយើងពិបាកណាស់ ។

កៈ
ចាអញ្ចឹងអរគុណច្រើនបងតើឥឡូវនិងតើពួកគាត់និងប្រកបរបរអ្វិហើយរស់នៅកន្លែងណាដែលបង?

ខៈ ពួកគាត់នៅកំពង់ធំនៅ តាំងគោទាំងអស់ពួកគាត់ជាអ្នកដែលធ្វើស្រែនិងចំការ?

កៈ អញ្ចឹងពួកគាត់និងរស់នៅខេត្តនិងទាំងអស់មែនបង?

ខៈ និងហើយពួកគាត់គឺនៅខេត្តទាំងអស់និង។

កៈ ហើយចុះឪពុកម្តាយរបស់គាត់និងគឺពួគគាត់និងមានឈ្មោះអ្វីដែលបង?

ខៈ ឪពុកគឺមានឈ្មោះថាសាយ ហ៊ុន។

កៈ ចុះឪពុកវិញ?

ខៈ ឪពុកឈ្មោះថាសាយ ហ៊ុន។

កៈ ចុះម្តាយវីញ?

ខៈ ម្តាយគាត់ឈ្មោះថា អ៊ុំ ភី។

កៈ ហើយតើពួកគាត់ទាំងពីនិងមានអាយុប៉ុន្មានហើយបង?

ខៈ ពុកតាំងពីគាត់និងស្លាប់ទៅនិងគាត់មានអាយុ64ហើយម៉ែគាត់ពុំតែ53ទេម៉ែ។

កៈ ចាបងហើយតើពួកគាត់និងកើតនៅចាំណាតើបងមាននៅចាំដែលទេបង?

ខៈ ដូចជាអត់ចាំផងនិង។

កៈ
ចាបងអរគុណច្រើនបងអញ្ចឹងចំពោះឆ្នាំច័ន្ទគិតតើពួកគាត់និងកើតនៅឆ្នាំណាដែលបង?

ខៈ ពុកគាត់ឆ្នាំរក្វា។

កៈ ឆ្នាំរក្សាម្ដាយឬក៏ឪពុកបងដែលកើតឆ្នាំរក្សានិងបង។

ខៈ ឪពុកគឺកើតឆ្នាំរក្សាហើយម្ដាយគាត់កើតឆ្នាំខាល។

កៈ អឺគាត់កើតឆ្នាំខ្លាអញ្ចឹងតើគាត់កើតដែលទេបង?

ខៈ អត់ទេម៉ែគាត់ស្លូតណាស់។

កៈ ចាបងចា។

ខៈ គាត់ជាមនុស្សដែលតស៊ូច្រើន។

កៈ ចាអញ្ចឹងតើបងមានដឹងថាពួកគាត់និងកើតនៅស្រុកណាខេត្តណាដែលទេបង?

ខៈ
និយាយចំទៅអត់ចាំផងនិងតែបើម៉ែគាត់នៅភូមិនៅនិងហើយស្រុកកំណើតគាត់និងគឺនៅកន្លែងនិងតែម្ដង។

កៈ ស្រុកកំនើតរបស់គាត់នៅភ្នំពេញ?

ខៈ អត់ទេនៅស្រុកនៅតាំងគោលនិង នៅភូមិក្លុយកើត ស្រុកបារ៉ាយ ខេត្តកំពង់ធំ។

កៈ ខេត្តកំពង់ធំនិងអញ្ចឹងចុះឪពុកវិញ?

ខៈ ឪពុកដូចជាអត់ចាំផងពុកដូចជាមិនឆ្ងាយអីប៉ុន្មានទេដូចចានៅជិតៗនិងដែលនិង។

កៈ ហើយចុះតើឪពុករបស់បងនិងគាត់ប្រកបកអ្វីសម្រាប់ចិញ្ចឹងជីវិតដែលបង?

ខៈ គាត់ជាជាងផ្ទះផងគាត់ជាអ្នកដែលធ្វើស្រែផង។

កៈ ចុះម្ដាយវិញបង?

ខៈ ម្ដាយគាត់ជាអ្នកដែលធ្វើស្រែចំការដែល។

កៈ ចុះ?

ខៈ
ពួកគាត់អត់មានបានធ្វើអ្វីផ្សេងពីនិងទេគាត់ជាអ្នកធ្វើស្រែធ្វើចំការនិងស៊ីឈ្នួលគេធ្វើស្រែធ្វើចំការ។

កៈ
អញ្ចឹងតើបងមានដឹងថាតើឪពុករបស់បងកាចឬក៏ស្លូតឬក៏គាត់ជាមនុស្សដែលស្លាប់ហេតុផងអីដែលទេបង?

ខ៖
គាត់ជាមនុស្សស្លូតណាស់ហើយគាត់អត់ចេះដើរទៅញុំាស្រាអីទេហើយពេលដែលគាត់និងកាចពេលដែលកូននិងវាខូចអីដែលបានគាត់និងកាចដាក់ទេបងខូចនិងធ្វើអីមួយអោយត្រូវរឿងគាត់អត់ដែលកាចដាក់អីនោះទេ
ពេលនៅជិតជាមួយនិងប្រពន្ធកូនអីនិងគឺគាត់និងស្លូតបំផុតតែបើម៉ែគាត់រៀងកាច។

ក៖ ចុះតើពួកគាត់ជាមនុស្សដែលស្ដាប់ហេតុផងដែលទេបង?

ខ៖ គាត់កាចតែគាត់ស្ដាប់ហេតុផងរបស់យើង?

ក៖ ចាអញ្ចឹងតើបងមាននៅចងចាំសាច់រឿងអីជាមួយនិងឪពុកម្ដាយរបស់បងដែលទេបង?

ខ៖
ចាំចាំចាំថាពីរនាក់ប្ដីប្រពន្ធគាត់និងគឺស្រលាញ់គ្នាខ្លាំងណាស់ជាមនុស្សស្រលាញ់កូននិងប្រពន្ធមិនចេះនេះមិនចេះនោះអីទេក៏មិនចេះរករឿងកូនអត់ចេះរករឿងប្រពន្ធអីទេមិនថាតែស្រាក៏គាត់និងអត់ចេះហូបដែលនិងបើម្ដាយខ្ញុំគាត់ជាអ្នកដែលតស៊ូហើយគាត់និងស្រលាញកូននិងស្រលាញ់ចៅខ្លាំងណាស់ដឹងទេទោះជាកូននិងខុសយ៉ាងណាក៏ដោយក៏គាត់មិនចេះរករឿងអីដែលទាល់តែកូននិងវាខុសខ្លាំងទើបគាត់ហៅមកសួរនាំអីអញ្ចឹងទៅហើយក៏មិនដែលវាយអីកូនដែលស្រលាញ់ម៉ែត្រង់និងហើយពុកវិញគឺស្លូតណាស់ដឹងទេ។

ក៖
ចុះតើពួកគាត់មានដែលប្រាប់បងអំពីរឿងរបស់ពួកគាត់កាលពីគាត់នៅក្មេងដែលទេបង?

ខ៖
គាត់ធ្លាប់និយាយតាថាជីវិតរបស់គាត់និងធ្លាប់ក្រធ្លាប់ពិបាកអីអញ្ចឹងទៅហើយគាត់និងក៏មិនចង់អោយកូនៗនិងលំបាកដូចជាពួកគាត់ហើយគាត់និយាយថាប្រវិត្តរបស់ពុកម៉ែនិងគឺវេតតានាណាស់ពីជំនាន់និងបានដុបអង្គរដុបអីអញ្ចឹងទៅហើយគាត់ចេះតែកុំអោយកូននិងភ្លេចពីរឿងពីដើមអីអញ្ចឹងទៅណាគាត់ចង់លំរឹកកូនរឿងអីអញ្ចឹងទៅនិងអារឿងស្អីៗនិងប្រាប់យើងកុំអោយយើងនិងភ្លេចដូចជាអារឿងវិចនំវីចអីនិងបង្រៀនកូននិងទាល់តែចេះ។

ក៖
ហើយមួយទៀតដែលបងតើគាត់មានដែលនិយាយពីជំនាន់ពលពតប្រាប់បងដែលទេបង?

ខ៖ ប្រាប់ប្រាប់។

ក៖
ហើយមួយទៀតតើជំានាន់និងតើពួកគាត់និងរស់នៅពីបាកយ៉ាងមិចខ្លះអត់ឃ្លាយ៉ាងមិចខ្លះ
ដែលតើបងអាចជួយជំរាបខាងប្អូនបន្តិចបានទេបង?

ខ៖ ដូចជាអត់សូវចាំអីទេព្រោះអីពីមុននិងគឺនៅតូចៗពេក។

ក៖ និងហើយនិងហើយតែបងអាចនិយាយបានទេនៅអ្វីដែលបងនៅចាំនិងនៅដឹងបង?

ខ៖
ចាំពេលនិងគឺខ្ញុំនិងនៅតូចៗដូចជាតូចដែលនិងតែដឹងថាពួកអាពតនិងវាចូលមកអីអញ្ចឹងដូ
ចជាពួកវានិងបានផ្លោគ្រប់មកហើយគ្រប់និងបានត្រូវតារបស់ខ្ញុំត្រូវតាខ្ញុំគឺត្រូវពោះរបស់តារ
បស់ខ្ញុំនិងហើយពេលដែលយើងដេកនិងបានក្រលស្រារបស់តាខ្ញុំនិងគាត់ទុកនៅកន្លែងនិ
ងពេលមានគ្រាប់ផ្លោមកខ្ទិចអស់ក្រលស្រានិងិងពួកយើងនិងគឺចាំបានត្រង់និងគាត់បាននិ
យាយបើគ្នាក្រលស្រានិងទេកូននិងទៅងាប់ព្រោះអីខ្ញុំគេងនៅកន្លែងនិងគាត់បានបីយើងរត់
ព្រោះពេលនិងពួកវានិងបានចូលមកគាត់ក៏បានបីយើងនិងរត់ទៅអញ្ចឹងយើងគ្រប់តែគិតមើ
លថាពីមុននិងវាយ៉ាងមិចចំពោះជំនាន់មុនវិញគឺគេបានបរអាទៀសគឺអីនិងទៅក្នុងព្រៃអីនិង
គុំដើមចេញអីអញ្ចឹងទៅគាត់និាយយតែអញ្ចឹងទេហើយគាត់បាននិាយយថាអោយពិបាន
ណាស់ព្រោះអីត្រូវត្រូវគ្រាប់ផ្លោអីទៀតងដល់ហើយចាំតែប៉ុន្មានកាលពីជំនាន់និងពិបាក
ណាស់?

ក៖
ចាអញ្ចឹងដល់ពេលមកដល់ជំនាន់ពល់ពតនិងតើអ្នកមីងមានរស់នៅជួបជុំគ្រួសារដែលទេអ្ន
កមីងនៅពេលជំនាន់អាពតនិងអ្នកមីង?ចង់មានន័យថាពេលដែលវាជំលៀសយើងអោយម
កនៅជាមួយនិងពួកវានិងហើយ។

ខ៖ នៅនៅជុំគ្នា។

ក៖
ដល់ពេលនៅជុំគ្នាអីអញ្ចឹងគេអត់បំបែកថាអ្វកុមារទៅផ្សេងក្មេងទៅផ្សេងចាស់ទៅផ្សេងអីអ
ញ្ចឹងទេន៍?

ខ៖ គាត់ធ្លាប់ធ្វើអញ្ចឹងតែជំនាន់ពួកខ្ញុំអត់អញ្ចឹងទេជំនា
ន់ពួកខ្ញុំនិងគឺផុតបាតហើយបើម៉ែខ្ញុំវិញគាត់ធ្លាប់និយាយថាគាត់ធ្លាប់ជំលៀសទៅដល់គាត់
ថាពិបាកណាស់កងចល័តគាត់និងចុះឡើងចុះឡើងគាត់ថាពីបាកណាស់មើលទៅគាត់និ
យាយមកថាពិបាកណាស់។

ក៖
ចាអញ្ចឹងអរគុណច្រើនអញ្ចឹងតើបងមាននៅចាំឈ្មោះជីដូននិងជីតារបស់បងដែលទេបងថាពួកគាត់មានឈ្មោះអ្វីដែលបង?

ខ៖ ចាំតើចាំតែពុកម៉ែខាងយាយហើយអត់ចាំត្រគោលទៀតចាំតែឈ្មោះ។

ក៖ គាត់មានឈ្មោះអ្វីដែល?

ខ៖ គាត់ឈ្មោះថាតាហិន ហើយយាយគាត់ឈ្មោះថាយាយឡេង។

ក៖ ទាំងអស់និងគឺពួកគាត់និងខាងម្ដាយមែនទេបង?

ខ៖ ចានិងហើយខាងម្ដាយតែបើ។

ក៖ ហើយចុះខាងឪពុកវិញ?

ខ៖ ឪពុកដូចជាអត់ស្គាល់ផងនិងអត់ចាំឈ្មោះផងនិង។

ក៖ ចុះបងមានដឹងថាពួកគាត់កើតនៅក្នុងឆ្នាំខែណាថ្ងៃណាដែលទេបង?

ខ៖ អត់ចាំផងនិង?

ក៖ ចុះគាត់កើតនៅស្រុកណាហើយគាត់ជាអ្នកស្រុកណាដែលខាងតាយាយ?

ខ៖
ខាងតាយាយដូចជាអត់ដឹងប្រវិត្តរបស់គាត់អីទេអត់ដឹងថាពួកគាត់និងកើតនៅកន្លែងណាអីផងនិងតែពេលដែលខ្ញុំនិងដឹងក្ដីមកគាត់ថាពួកគាត់នៅកន្លែងនិងតាំងពីនេះមកម្ល៉េះ។

ក៖
ហើយចុះបងមានដែលចាំសាច់រឿងអ្វីដែលពួកគាត់បានប្រាប់ដល់បងដែលទេបងជីដូននិងជីតាបង?

ខ៖ កើតអត់ទាត់ផងនិងពួកគាត់ស្លាប់អស់ហើយនិង

ក៖
ចាអស់គុណច្រើនបង?ចាអញ្ចឹងតើក្រុមគ្រួសាររបស់បងរស់នៅទីក្រុងភ្នំពេញអស់រយះពេលយូរប៉ុនណាហើយបង?

ខ៖
អឺខ្ញុំពុំតែមកនៅនិងពេលដែលខ្ញុំបានប្ដីនិងខ្ញុំក៏មកនៅនិងកាលនិងខ្ញុំនៅស្រុកនៅអឺតាំងគោលខេត្តកំពង់ធំនិង។

ក៖ ចាចាចាតែបងនៅទីនេះអស់រយះពេលប៉ុន្មានឆ្នាំហើយបង?

ខ៖ ពុំមកនៅបានពីរឆ្នាំអីនិង។

ក៖
ពីរឆ្នាំអញ្ចឹងពេលដែលបងនៅខេត្តនិងគឺបងបានរស់នៅតាំងពីតូចរហូតដលបងមានប្តីមែនទេបង?

ខ៖
ចាចានិងហើយតែពេលយើងមកធ្វើការអីនៅភ្នំពេញយូរទៅហើយបានមកនៅទីនេះជាប់។

ក៖
ចាអរគុណច្រើនបងហើយអញ្ចឹងតើបងមានបងប្អូនឬក៏សាច់ញ្ញាតិអីដែលរស់នៅក្រៅប្រទេសដែលទេបង?

ខ៖ អត់មានផងនិង។

ក៖ អត់សោះតែម្តងមែនបងហើយចុះខាងប្តីរបស់បងវិញ។

ខ៖ ក៏អត់មានដែល។

ក៖ អរគុណច្រើនបងហើយតើអញ្ចឹងតើបងមានកូនប៉ុន្មានអ្នកដែលហើយបង?

ខ៖ បងមានកូនចំនួនបួនអ្នកហើយនិង។

ក៖ អូភ្លេចសួរតើបងបានរៀបការហើយនៅបង?

ខ៖ ហើយហើយ។ហើយក៏មានកូនចំនួនបួនអ្នកដែល។

ក៖ ហើយស្រីប៉ុន្មានប្រុសប៉ុន្មានដែល។

ខ៖ ស្រីពីរប្រុសពីរ។

ក៖ ហើយខ្ញុំចង់សួរសំនួរទៀតថាតើស្វាមីរបស់បងមានឈ្មោះអ្វីដែលទៅបង?

ខ៖ ពែងមែនចិត្រ។

ក៖
តើបងរៀបអាពាហ៍ពិពាហ៍និងនៅពេលណាដែលបង?ដូចជានៅឆ្នាំណាខែណាអីអញ្ចឹងបង?

ខ៖
ដូចជាភ្លេចបាត់នាគតែតាំងពីរពាន់ជាងមកម្លេះដូចជាពីរពាន់ប្រាំមួយនិងពីរពាន់ប្រាំពីរមក
ម្ល៉េះ។

ក៖ អរគុណច្រើនបងតើបងរៀបចំអាពាហ៍ពិពាហ៍និងនៅទីក្រុងភ្នំពេញឬក៏នៅខេត្តបង?

ខ៖ នៅខេត្ត។

ក៖ ខេត្តអ្វីដែលបង?

ខ៖ នៅភូមិខ្លុយកើត ឃុំ ស្រូយោង ស្រុកបារាយ ខេត្តកំពង់ធំ។

ក៖
ចាអរគុណច្រើបងអញ្ចឹងតើអាពាហ៍ពិពាហ៍របស់បងនិងរាប់ចំដោយចាស់ទុំឬក៏ការស្រលា
ញ់គ្នាដោយចិត្តខ្លួនបងដូចបានរៀបការដោយខ្លួនឯងអីអញ្ចឹងបងឬក៏ចាស់ទុំជាអ្នកចាប់ថៃ
ងអីអោយអញ្ចឹងបង?

ខ៖
អត់ទេដូចជាពេលដែលពួកយើងនិងស្រលាញ់គ្នាអីអញ្ចឹងទៅបានចាស់ទុំនិងគេទៅសួរនាំ
យើងនិងតាមក្រោយទៀតអញ្ចឹង។

ក៖
ចាអញ្ចឹងមានន័យថាបងបានស្គាល់គ្នាជាមួយនិងបងប្រុសហើយបងប្រុសក៏បាននាំឪពុក
ម្ដាយរបស់ពួកគាត់និចូលមកស្ដីដណ្ដឹងបងស្រីតាយរយៈឪពុកម្ដាយរបស់បងតាមផ្លូវច្បាប់
ហើយបងតើជំនាន់និងមានថ្លៃជំនួនអីដែលទេបង?

ខ៖ បានតា។

ក៖ ថ្លៃជំនូននិងមានចំនួនប៉ុន្មានដែលបង?

ខ៖ បានប្រាំរយះ។

ក៖
ប្រាំរយះដុល្លាចាវានេះដែលបងវាច្រើនដែលបងហើយតើបងអាចប្រាប់ខ្ញុំបានទេបងថាពេ
លដំបូងដែលបងបានជួបជាមួយនិងបងប្រស់ពេលដែលបងបានជួបជាមួយនិងគាត់ថាតើ
បងធ្វើយ៉ាងមិចទើបបានជួបគាត់រហូតដល់មានចំនងអាពាហ៍ពិពាហ៍និងរហូតដល់មានកូន
ដល់ទៅបួននាក់តើបងអាចប្រាប់ខ្ញុំបានទេបង?

ខ៖
ប្រាប់បានតាពីរដំបូងនិងគឺពួកយើងនិងធ្វើការហើយពួកយើងនិងបានជួយគ្នាអីអញ្ចឹងទៅណាតែគ្រាន់ថាពេលដែលយើងនិងធ្វើការនិងយើងស្គាល់គ្នាធម្មតានិងមិនទាន់ចេះស្រលាញ់គ្នាអីខ្លាំងណាចេះតែប្រអាប់ចុះប្រអាប់ឡើងអញ្ចឹងដល់ពេលដែលយើងប្រអាប់ចុះប្រអាប់ឡើងអីអញ្ចឹងទៅយើងក៏បាក់ចិត្តស្រលាញ់គ្នាអីអញ្ចឹងទៅហើយស្រលាញ់គ្នាអីនិងប្រហែលជាកន្លះឆ្នាំបានចាស់ទុំអីនិងចូលស្ដីនាំអីអោយនិងហើយបានប្រហែលជាពីរខែបានអីពេលដែលគេនិងចូលស្ដីហើយនិងប្រហែលជាបានពីរទៅបីខែបានពួកយើងនិងចាប់ផ្ដើមរៀបការបានខ្ញុំចាប់ផ្ដើមរៀបការនៅថ្ងៃទី02 ខែទី03
តែអត់ដឹងថាពីរពាន់ប៉ុន្មានទេភ្លេចបាតហើយដូចជាពីរពាន់ប្រាំពីរមិនដល់ឬក៏ពីពាន់ប្រាំពីរអីមិនដឹងទេ។

ក៖ ចាអរគុណច្រើនបងតើបងចេះអាននិងចេះសរសេរភាសាខ្មែរបានល្អប៉ុណ្ណាដែលបង?

ខ៖ ខ្ញុំបានត្រឹមថ្នាក់ទីប្រាំពីរ។

ក៖ ដូចជាចេះអាននិងចេះសរសេរបានច្បាស់ល្អអត់បង?

ខ៖ សរសេរបានច្បាស់ហើយពេលអាននិងក៏ច្បាស់ដែល?

ក៖
ចាឡូយមែនទែនហើយតើបងមានចេះភាសាក្រៅដូចជាភាសាចិននិងភាសាជប៉ុនអីក្រៅដែលទេបង?

ខ៖ អត់ផងនិង។

ក៖ អញ្ចឹងមានន័យថាបងចេះតែភាសាខ្មែរតែមួយទេមែនទេបង?

ខ៖ ចាអត់ចេះទេភាសាក្រៅ។

ក៖ ចាអញ្ចឹងតើបងរៀនបានកំរិតថ្នាក់ទីប៉ុន្មានដែលបង?

ខ៖ បានត្រឹមថ្នាក់ទីប្រាំពីរ។

ក៖ ហើយតើបងរៀននៅសាលាណាដែលបង?

ខ៖ នៅសាលាបឋមសិក្សាបណ្ដុះវិជ្ជា។

ក៖ នៅកន្លែងណាដែលបង។

ខ៖
នៅនេះនិងគឺនៅភូមិចិត្តនិង។នៅភូមិយើងអីនិងអត់មានទេសាលានៅជិតនិងមានតែទៅរៀននៅនិង។

ក៖ ចឹងតើបងរៀននៅសាលាណាដែលបងតើបងអាចបញ្ជាក់ឈ្មោះបានទេបង?

ខ៖ នៅអឺបឋមសិក្សាបណ្តុះវិជ្ជា។

ក៖ នៅខេត្តណាដែលបង។

ខ៖ នៅតាំងគោលនិងគឺនៅកំពង់ធំនិង។

ក៖
អញ្ចឹងតើបងធ្លាប់មានមិត្តភក្តិដែលធ្លាប់ធំធាត់មកជាមួយនិងគ្នាដែលទេបងជាមិត្តភក្តិស្និតស្នាដែលរួមសុខទុកជាមួយនិងបងតើមានដែលទេបង?

ខ៖ អត់មានផងនិង។

ក៖ ហើយចុះតើបងមានមិត្តផ្សេងដែលទេបង។

ខ៖ ស្គាល់តែដូចជាអត់សូវចាំទេព្រោះឥឡូវនិងពួកគេមានប្តីមានអីអស់ហើយនិង។

ក៖ អញ្ចឹងតើបងមាននៅចាំឈ្មោះរបស់ពួកគាត់ដែលអត់បង?

ខ៖ ចាំតា។

ក៖ អាចជួយប្រាប់ឈ្មោះរបសពួកគាត់អោយខ្ញុំបានដឹងផងបានទេបង?

ខ៖ ពេជ្រ សាលៀន ។

ក៖ ហើយគាត់ស្រិឬក៏ប្រុសដែលបង?

ខ៖ ស្រី។

ក៖
អូគាត់ស្រិ។ហើយពេលដែលបងរៀនជាមួយនិងគាត់និងតើបងមានអនុស្សាវរីន៏អ្វីខ្លះជាមួយនិងគាត់អ្វីខ្លះដែលបង។ដូចជាពេលដែលទៅរៀនអីជាមួយនិងគាត់មានដែលវិចបាយទុកញ៉ាំអីជាមួយនិងគាត់ដែលទេបង?

ខ៖
អត់ដែលវិចបាយញ៉ាំអីជាមួយនិងគ្នាទេតែនៅពេលដែលចេញពីរៀនពួកយើងទៅរៀនជាមួ

យនិងគ្នាពេលត្រលប់មកវិក៏ទៅជាមួយនិងគ្នាពេលដែលលេងអីក៏លេងជាមួយនិងគ្នាដែល តែឥឡូវដូចជារាងឆ្ងាយតិចហើយពួកគេមនាប្តីមានកូនដែលពេលជួយគ្នាម្តងៗគេនិយាយ ថាពេលដែលគេការហើយនិងគេបានកូនភ្លោះ។

ក៖ អឺកូនភ្លោះ។

ខ៖ និងហើយកូនភ្លោះប្រុសដល់ទៅពីរ។

ក៖ ហើយតើបងធ្លាប់ធ្វើការងារនៅវាស្រែដែលទេបង?

ខ៖ ធ្លាប។

ក៖ តើបងធ្លាប់ធ្វើការងារអ្វីខ្លះដែលទៅបង។

ខ៖ យើងធ្វើស្រែគឺយើងដក់ស្ទង់ដល់ពេលច្រូតស្រូវអញ្ចឹងទៅយើងទៅច្រូតទៅ។

ក៖ តើបងធ្លាប់ធ្វើអាជីវកម្មជាអ្នកលក្ខណៈគ្រួសារដែលទេបង។

ខ៖ អត់ផងនិង។

ក៖ អញ្ចឹងបងធ្លាប់ធ្វើការងារអ្វីខ្លះនៅក្នុងជីវិតរបស់បង?

ខ៖
ធ្លាប់ធ្វើការងាររាងចក្រហើយធ្លាប់ធ្វើការនៅចំការពេលទៅរើសស្វាយច័ន្ទទីអញ្ចឹងទៅហើ យជួយដាំនេះដាំនេះគេអញ្ចឹងទៅមានតែប៉ុននិង។

ក៖ ហើយពេលផុតលូវនេះតើជីវិតរបស់បងមានកាផ្លាស់ប្តូរអ្វីខ្លះដែលទៅបង?

ខ៖
ខ្ញុំមានការផ្លាស់ប្តូច្រើនព្រោះអីពេលដែលយើងនៅតែម្នាក់យើងយើងអត់សូវពិបាកច្រើនអី ទេមកពេលដែលយើងមានកូនមានចៅយើងពីបាកច្រើនយើងមិនបានរកស៊ីជាមួយគាត់រក តែម្នាក់គាត់ហើយណាមួយទៀតយើងមានកូនតូចអញ្ចឹងយើងអត់អាចជារកគាត់អីបានទេ វាពិបាក។

ក៖ តើម្ហូបអ្វីខ្លះដែលបងចូលចិត្តជាងគេដែលបង?

ខ៖ មុខម្ហូបដែលបងចូលចិត្តជាងគេគឺសំម្លមជូរ

ក៖ អោយតែមជូរបងចូលចិត្តទាំងអស់មែនបង?

ខ៖
និងហើយព្រោះអីយើងនៅស្រុកស្រែយើងអញ្ចឹងហើយបើនៅស្រុកស្រែវិញចង់រាល់ថ្ងៃមជូរអោយតែបានជូរហុតអត់អីក៏បានដែល។

ក.	ហើយអញ្ចឹងប្ដីរបស់បងអីក៏គាត់ញ៉ាំដែលមែនបងគាត់ញ៉ាំអត់រើសមែនបង។

ខ៖
រើសដែលសំម្លរកូគោអត់ចេះទេនិងសម្លរប្រហើរនិយាយចំរើសច្រើនណាស់ខុសពីយើងពេលយើងដាក់ម្ហូបអីក៏យើងចូលចិត្តដែលគាត់ថាយើងចំនងចំនូលចិត្តនិងខុសគ្នាចាអរគុនច្រើនបង។

ក៖ អញ្ចឹងតើល្បែងប្រជាប្រិយណាមួយដែលបងចូលចិត្តលេងជាងគេដូចជាបោះឈូកទាញព្រត់
លាក់កន្សែងអីញ្ចឹងបងតើល្បែងប្រជាប្រិយរបស់ខ្មែរតើបងចូលចិត្តលេងអ្វីដែលបង?

ខ៖ បងចូលចិត្តលេងចោលឈូស។

ក៖ ហើយមានអ្វីទៀតដែលទេបង?

ខ៖ បោះឈូកហើយបោះអង់គុញ។

ក៖
មួយនិងតើបងលេងវាតាំងពីក្មេងឬក៏បន្តលេងដល់ពេលដែលបងធំនៅតែលេងវាទៀតអញ្ចឹងបងអោយតែបុណ្យចូលឆ្នាំក៏នៅតែបន្តលែង?

ខ៖
នៅបន្តលេងទោះជាចូលឆ្នាំក៏ដោយលេងជាប់រហូតនិយាយរួមទៅពេលដែលចូលឆ្នាំអីនិងពួកយើងលេងរហូតនិងមានកូនក៏យើងអាចលេងបានដែល។

ក៖ អូនិងខ្ញុំចង់សួរមួយនិង។គេអត់ប្រកាន់ទេ។

ខ៖ អត់ប្រកាន់អីនោះទេ។

ក៖ ចាអញ្ចឹងតើបងមានចំាបទចរៀងអ្វីដែលបងធ្លាប់ចងចាំតាំងពីក្មេងដែលទេបង?

ខ៖ ចាំចាំអាបទចំរៀងដែលគេច្រៀងថាចោលឈូកនិងអូ។

ក៖ និងហើយអ្នកណាជាអ្នកច្រៀងដែលបង?

ខ៖
អ្នកចាស់គាត់ច្រៀងហើយគាត់ដូចជាពេលដែលយើងលេងអីអញ្ចឹងទៅមានចាស់ចាស់គាត់ច្រៀងបទនិងអោយអីញ្ចឹង។

ក៖ ចានិងហើយតើបងចូលចិត្តស្តាប់បទចំរៀងអ្នកណាច្រៀងដែលបង?

ខ៖ ចំរៀងសម័យឥលូវនិងមែន?

ក៖ មិនថាបទណាទេអោយតែថាបងចូលចិត្តអីញ្ចឹងបង។

ខ៖ ចំរៀងចូលចិត្តពីដើមៗបទអឺស៊ុន ស៊ីសាមុត រស់ សិរីថ្ងអឺនិងបទពីដើមនិង។

ក៖ បងស្គាល់ចំណាងយើងដែលអត់បង?

ខ៖ អត់សូវចាំអិនោះទេ។

ក៖ ងគ្រួសាររបស់បងតើមានអ្នកណាដែលចេះលេងឧបករណ៏ដែលទេបង។

ខ៖ អត់មានផងនិង។

ក៖ ចុះប្តីរបស់បងតើគាត់ចេះអត់បង?

ខ៖ អត់ផងគាត់អត់ចេះផងនិង។

ក៖ ចុះផ្ទះរបស់មានលក្ខណះយ៉ាងមិចដែលបង?

ខ៖ ផ្ទះនៅតាមខេត្តមែន?

ក៖ ផ្ទះនៅតាមខេត្ត?

ខ៖ ផ្ទះក្បឿងពីរខ្នងពុំធ្វើដែលរកលុយបានដែលនិង។

ក៖ ពុំធ្វើមែន។

ខ៖ ធ្វើហើយធ្វើហើយបានប្រហែលជាមួយឆ្នាំបានពុកគាត់ស្លាប់។

ក៖ ហើយចុះឥឡូវនិងផ្ទះនៅពេញជាផ្ទះរបស់ខ្លួនបងឬក៏របស់អ្នកណាដែលបង?

ខ៖ ផ្ទះរបស់ម្តាយក្មេម។

ក៖ ហើយតើផ្ទះនិងមានលក្ខណះយើងមិចដែលផ្ទះមួយនិងបង?

ខ៖ ផ្ទះនិងគឺផ្ទះថ្ម។

កៈ
ចាអរគុណច្រើនបងចឹងផ្ទះរបស់បងគឺផ្ទះថ្មហើយទ្វាប៉ាងអាសង្គីហើយខ្ញុំចង់សួរបងមួយទៀតតើបងអាចប្រាប់ខ្ញុំបានទេពីការលំបាករបស់បងបងមានការលំបាកអ្វីខ្លះដែលបង?

ខៈ
លំបាកច្រើនណាស់រស់នៅពីបាកណាស់ព្រោះអីយើងខ្វះខាតមុខក្រោយហើយណាមួយកូនយើងវាតូចហើយវាឈឺឈឺហើយឈឺច្រើនទៀតកូនស្រីពីបងនិងងនោះវិញអត់ដែលឈឺអីទេតែបើកូនបងពីនេះវិញពូកែឈឺណាស់រកលុយបានអីមើលតែជំងឺវានិងបើលុយមកអីនិងអត់ដែលសល់ទេនៅតែប្រឹងទៅធ្វើការងារទៀតហើយខំប្រឹងដើម្បីកូនតទៀត។

កៈ
ចាអរគុណច្រើនបងអញ្ចឹងចូលមកបទពិសោធន៍ដែលល្អៗវិញតើបងមានបទពិសោធន៍ល្អៗនិងអ្វីខ្លះដែលបង?

ខៈ មិនដឹងនិយាយថាមិចទេអាល្អៗនិង។

កៈ
ដូចជាពេលឥឡូវនិងបងមានស្វាមីហើយបងសប្បាយចិត្តអីអញ្ចឹងបងហើយជីវភាពរបស់គ្រួសារក៏អត់ដូចជាពីមុនដែលអញ្ចឹងតើបងអាចជួយរៀបរាប់បានទេបង?

ខៈ មិនដឹងថានិយាយមិចផង។

កៈ
ចាអរគុណច្រើនបងអញ្ចឹងនៅពេលដែលនៅពីក្មេងតើបងចង់ធ្វើអ្វីដែលបងដូចជាកាលដែលបងនៅពីក្មេងពេលដែលបងទៅរៀននិងតើបងចង់ក្លាយជាគ្រូបង្រៀនឬក៏ជាគ្រូពេទ្យ។

ខៈ
ចង់តើយើងអត់មានលុយរៀនទៀតជីវភាពយើងក៏អត់សូវមានលុយហើយយើងខ្វះខាតអញ្ចឹទៅអត់បានរៀនត។

កៈ
អរគុណហើយបើបងមានអ្វីចង់ផ្តាំផ្ញើរទៅកាន់កូនចៅជំនាន់ក្រោយហើយបងចង់និយាយអ្វីទៅកាន់ពួកគាត់បង?

ខៈ
ចង់និយាយថាអោយកូនចៅជំនាន់ក្រោយនិងខំរៀនប្រឹងរៀនសូត្រអោយល្អហើយថាអោ

យពួកគាត់និងខំប្រឹងរៀនខំប្រឹងសូត្រអញ្ចឹងទៅអោយមានចំនេះដឹងនិងនៅក្នុងខ្លួនហើយដើម្បីអោយប្រទេស់របស់យើងនិងរីកចំរើនទៅដល់ថ្ងៃខាងមុខ។

កៈ ចាអរគុណច្រើនហើយអញ្ចឹងបងអ្នកមីងមានអ្វីចង់បន្ថែមទៀតដែលទេអ្នកមីង។

ខៈ អស់ហើយនិង។

កៈ
អស់ហើយអញ្ចឹងខ្ញុំក៏អរគុណដឹងបងដែលផ្តល់បទសំភាស៍ដល់ខ្ញុំហើយខ្ញុំសូមថ្លៃអំណរគុណដល់អ្នកមីងហើយខ្ញុំសូមថតរូបបងដើម្បីទុកអោយសកលវិទ្យាល័យនិងផងដែលបានទេបង?

ខៈ បានអូនបាន។

កៈ ចាអរគុណបងជំរាបលា។